**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តក្រចេះ**
លេខៈ០៩៣/១៦ សសរ

ក្រចេះ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពគណៈកម្មាធិការខេត្តក្រចេះ ជំរុញចលនាភូមិ១ ផលិតផល១

## អភិបាលខេត្តក្រចេះ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៦/៥៦៦ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការតែងតាំងអភិបាល នៃគណៈអភិបាលខេត្តក្រចេះ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៣/១០៥៩ ស្តីពីការផ្ទេរគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ ដោយធ្វើសមាហរណកម្មការងារជំរុញចលនាភូមិមួយ ផលិតផលមួយ ឲ្យស្ថិតនៅក្រមការទទួលខុសត្រូវនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និង ក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងលិខិតលេខ ០២៩ ភ.១ ផ.១ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ស្តីពីការណែនាំឲ្យរដ្ឋបាលរាជធានី ខេត្តរៀបចំគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ
- យោងតាមតម្រូវការចាំបាច់ខេត្តក្រចេះ ។

## សម្រេច

**ប្រការ១**.-

ត្រូវបានកែសម្រួលសមាសភាព គណៈកម្មាធិការខេត្តជំរុញចលនាភូមិមួយ ផលិតផលមួយ សរសេរអក្សរកាត់ថា " គ.ខ.ភ១.ផ១ " ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **សរ ចំរុង** | អភិបាលខេត្ត | ជាប្រធាន |
| ២- លោក | **ខ័ណ្ឌ ចំណាន** | អភិបាលរងខេត្ត | ជាអនុប្រធាន |
| ៣- លោក | **គុយ ហួត** | ប្រធានមន្ទីរកសិកម្មខេត្ត | ជាសមាជិក |
| ៤- លោក | **នី ធុន** | ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត | ជាសមាជិក |
| ៥- លោក | **ស៊ុំ ស៊ីណារ៉េន** | ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត | ជាសមាជិក |
| ៦- លោក | **រុន តារ៉ា** | ប្រធានមន្ទីរទេសចរណ៍ខេត្ត | ជាសមាជិក |
| ៧- លោក | **យិន វណ្ណៈ** | អភិបាលក្រុងក្រចេះ | ជាសមាជិក |
| ៨- លោក | **សុម សារិត** | អភិបាលស្រុកសំបូរ | ជាសមាជិក |
| ៩- លោក | **ហេង សុថា** | អភិបាលស្រុកឆ្លូង | ជាសមាជិក |
| ១០- លោក | **ហាច់ ចាន់ឌី** | អភិបាលស្រុកចិត្របុរី | ជាសមាជិក |
| ១១- លោក | **គង់ គីមនី** | អភិបាលស្រុកស្នួល | ជាសមាជិក |
| ១២- លោក | **សេក ម៉ីនហេង** | អភិបាលស្រុកព្រែកប្រសព្វ | ជាសមាជិក |
| ១៣- លោក | **អ៊ឹម ពិសី** | នាយករងរដ្ឋបាលសាលាខេត្ត | ជាសមាជិក |
| ១៤- លោក | **ទេព វាសនា** | ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត | ជាសមាជិក |
| ១៥- លោក | **ឡាយ បូរ៉ា** | ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត | ជាសមាជិក |
| ១៦- លោក | **លឹម ជាវហាវ** | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត | ជាសមាជិក |
| ១៧- លោក | **ឈ្លាង សុខុន្ថា** | ប្រធានមន្ទីរសុខាភិបាលខេត្ត | ជាសមាជិក |
| ១៨- លោកស្រី | **ម៉ឺន ស៊ីថុត** | ប្រធានមន្ទីរកិច្ចការនារីខេត្ត | ជាសមាជិកា |
| ១៩- លោកស្រី | **ណៃ ធីតា** | ប្រធានមន្ទីរព័ត៌មានខេត្ត | ជាសមាជិកា |
| ២០- លោក | **គង់ សុជាតិ** | ប្រធានមន្ទីរផែនការខេត្ត | ជាសមាជិក |
| ២១- លោក | **ឆាយ ឌួងសារ៉ុង** | ប្រធានមន្ទីរបរិស្ថានខេត្ត | ជាសមាជិក |
| ២២- លោក | **ចាន់ សុគុណា** | ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត | ជាសមាជិក |
| ២៣- លោក | **កែវ កុសល** | ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត | ជាសមាជិក |
| ២៤- លោក | **កែវ សុទ្ធារិទ្ធ** | ប្រធានសភាពាណិជ្ជកម្មមណ្ឌលខេត្តក្រចេះ ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី | ជាសមាជិក |
| ២៥- លោកស្រី | **សំអាត មានិត** | នាយិការងរដ្ឋបាលសាលាខេត្ត | ជាលេខាធិការ |

**ប្រការ២**.- គណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ មានភារកិច្ចដូចខាងក្រោមនេះ ៖

- សម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយនឹងអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១
- ជំរុញចលនាភូមិ១ ផលិតផល១ ឲ្យទទួលបានជោគជ័យដើម្បីរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណ ជំហានទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល

- អភិវឌ្ឍធនធានមនុស្សទាក់ទងនឹងការជំរុញចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត ដើម្បីអនុវត្តចលនាភូមិ១ ផលិតផល១ ឲ្យទទួលបានជោគជ័យដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ កាត់បន្ថយចំណាកស្រុក លើកកម្ពស់ជីវភាពរស់នៅ និងគុណភាពជីវិតរបស់ប្រជាជនតាមសហគមន៍
- ចូលរួម និងដឹកនាំការសិក្សា ស្រាវជ្រាវផលិតផល ជាសក្ដានុពលនានាដែលមាននៅក្នុងខេត្ត ទាំងផលិតផលវត្ថុធាតុដើម ផលិតផលកែច្នៃ និងផលិតផលសេវាកម្ម ដើម្បីបញ្ចូលទៅក្នុងចលនាភូមិ១ ផលិតផល១ ដោយធ្វើយ៉ាងណាបន្តអភិវឌ្ឍផលិតផលទាំងនោះមានលក្ខណៈកាន់តែប្រសើរ កាន់តែពិសេស និងសមស្របតាមទីផ្សារទាំងក្នុងសហគមន៍ ក្នុងប្រទេស និងក្រៅប្រទេស
- ផ្សព្វផ្សាយឲ្យបានទូលំទូលាយពីសារៈសំខាន់នៃការជំរុញចលនាភូមិ១ ផលិតផល១ និងលើកទឹកចិត្តប្រជាជននៅតាមមូលដ្ឋានឲ្យចូលរួមគាំទ្រ និងអនុវត្តចលនានេះ
- សម្របសម្រួលជាមួយអង្គការ ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានានៅថ្នាក់ក្រោមជាតិ ដើម្បីជំរុញការអនុវត្តចលនាភូមិ១ ផលិតផល១
- សម្របសម្រួលរៀបចំអនុវត្តយន្តការតាមដានការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីផែនការសកម្មភាពជំរុញ ចលនាភូមិ១ ផលិតផល១
- រៀបចំបង្កើតសមាគម ឬសហគមន៍គាំទ្រចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត
- រៀបចំបង្កើតមជ្ឈមណ្ឌលភូមិ១ ផលិតផល១ នៅក្នុងខេត្ត សម្រាប់ធ្វើជាកន្លែងសិក្សាស្រាវជ្រាវបណ្ដុះបណ្ដាល ផ្សព្វផ្សាយ ប្រមូលផ្ដុំ និងដាក់តាំងបង្ហាញ ឬលក់ផលិតផលភូមិ១ ផលិតផល១
- រៀបចំបង្កើតអនុគណៈកម្មាធិការក្រុង ស្រុក ជំរុញចលនាភូមិ១ ផលិតផល១ ដោយសមាសភាព និងតួនាទីរបស់អនុគណៈកម្មាធិការនេះ ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធានគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១
- រៀបចំរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១ និងថ្នាក់ដឹកនាំខេត្ត និងចម្លងជូនមន្ទីរ ស្ថាប័នពាក់ព័ន្ធក្នុងខេត្ត ដើម្បីរួមសហប្រតិបត្តិការក្នុងការជំរុញចលនាភូមិ១ ផលិតផល១ ។

**ប្រការ៣**.- លេខាធិការដ្ឋានភូមិ១ ផលិតផល១ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- លោកស្រី | **សំអាត មានិត** | នាយិការងរដ្ឋបាលសាលាខេត្ត | ជាប្រធាន |
| ២- លោក | **ជា ទេព** | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្ត | ជាអនុប្រធានអចិន្ត្រៃយ៍ |
| ៣- លោក | **សៅ សុផល** | នាយករងទីចាត់ការអន្តរវិស័យ | ជាអនុប្រធាន |
| ៤- លោក លោកស្រី | | អភិបាលរងក្រុង ស្រុក ទទួលបន្ទុក | ជាអនុប្រធាន |
| ៥- លោក | **ម៉ែន រដ្ឋា** | នាយករងទីចាត់ការផែនការ និងវិនិយោគ | ជាសមាជិក |
| ៦- លោក | **ឈា ផល្លី** | មន្ត្រីការិយាល័យលេខាធិការក្រុមប្រឹក្សា | ជាសមាជិក |
| ៧- លោក | **ប៊ឹម រាសី** | មន្ត្រីការិយាល័យទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ | ជាសមាជិក |

**ប្រការ៤**.- ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ មានដូចខាងក្រោម ៖
- គណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ មានសិទ្ធិរៀបចំបែងចែក ភារកិច្ចទទួលខុសត្រូវលម្អិតបន្ថែមទៀតសម្រាប់ជំរុញចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត និងក្រុង ស្រុក របស់ខ្លួន
- គណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ មានលេខាធិការដ្ឋានមួយ ដឹកនាំដោយនាយក ឬនាយករងរដ្ឋបាលមួយរូប និងមានជំនួយការមួយចំនួនជាមន្ត្រីរដ្ឋបាលរបស់សាលាខេត្ត ទៅតាមការចាំបាច់ ដោយមានការឯកភាពពី ប្រធានគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១

- គណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ អាចអញ្ជើញតំណាងមន្ទីរ អង្គភាពផ្សេងៗទៀតក្នុងខេត្ត តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ តំណាងវិស័យឯកជន និងតំណាងសហគមន៍ ឬសមាគមចូលរួមប្រជុំផ្តល់យោបល់ ឬពិភាក្សាគ្នាក្នុងការអនុវត្តភារកិច្ចលើកកម្ពស់ចលនាភូមិ១ ផលិតផល១នៅក្នុងខេត្តរបស់ខ្លួន
- សមាជិកគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ ត្រូវចូលរួមប្រជុំរៀងរាល់ ៣ខែម្តង និងករណីពិសេសណាមួយតាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការខេត្ត ជំរុញចលនាភូមិ១ ផលិតផល១ ឬអនុប្រធានគណៈកម្មាធិការដែលត្រូវបានទទួលការផ្ទេរសិទ្ធិពីប្រធានគណៈកម្មាធិការ ។

**ប្រការ៥**.- រាល់សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៦**.- នាយករដ្ឋបាលសាលាខេត្ត ប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធ អភិបាលក្រុង ស្រុក និងឯកឧត្តម លោក លោកស្រី ដែលមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យទទួលបានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។ ⁄S

**អភិបាលខេត្ត**

**សរ ចំរុង**

**កន្លែងទទួល**

- ក្រសួងមហាផ្ទៃ
- អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១
- ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៦
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ